**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង រវាង**
**ក្រុមហ៊ុន ញូ អេរ៉ា (ខេមបូឌា) ខាសមៀ ថិកស្តាយ ឯ.ក**
**និង**
**ប្រតិភូបុគ្គលិក តំណាងកម្មករ និងប្រធានក្រុមគ្រប់ផ្នែក**
**ប្រចាំក្រុមហ៊ុន ញូ អេរ៉ា (ខេមបូឌា) ខាសមៀ ថិកស្តាយ ឯ.ក**
**ស្តីពី**
**ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ**
**ដោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារកូវីដ-១៩**

ថ្ងៃទីមួយ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងដប់បី និងសូន្យសូន្យនាទីរសៀល នៅក្រុមហ៊ុន ញូ អេរ៉ា (ខេមបូឌា) ខាសមៀ ថិកស្តាយ ឯ.ក ដែលមានអាសយដ្ឋានស្ថិតនៅ ផ្លូវលេខ២១អា ភូមិព្រែកព្រៃង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល បានរៀបចំការប្រជុំមួយរវាងក្រុមហ៊ុន ញូ អេរ៉ា (ខេមបូឌា) ខាសមៀ ថិកស្តាយ ឯ.ក និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ។

ក្នុងអង្គប្រជុំ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ អំពីស្ថានភាពបច្ចុប្បន្ន ប្រឈមមុខយ៉ាងខ្លាំងនូវ បញ្ហាកង្វះវត្ថុធាតុដើម និងមិនមានអ្នកបញ្ជាទិញ ព្រមទាំងរងផលប៉ះពាល់ជំងឺ COVID-19ផ្សេងៗ ដែលជាមូលហេតុធ្វើអោយផលិតកម្មមិនអាចដំណើរការបាន ។ ដូច្នេះក្រុមហ៊ុនបានសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន៤៦៥នាក់ ក្នុងចំណោមកម្មករ ៤៦៥នាក់ រយៈពេល ០២ខែ ដោយចាប់ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ និងចូលធ្វើការវិញនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតឯកភាពទទួលយកប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១.ភាគីក្រុមហ៊ុន ឯកភាពផ្តល់ប្រាក់ឧបត្ថម្ភចំនួន $30 (សាមសិបដុល្លារអាមេរិក) ក្នុងមួយខែ

កិច្ចប្រជុំនេះ បានចប់នៅវេលាម៉ោងដប់បួន និងសូន្យសូន្យនាទីរសៀល នៅថ្ងៃខែឆ្នាំដដែល ក្រោមកិច្ចព្រមព្រៀងគ្នាដោយស្មារតីយោគយល់គ្នា សហការគ្នា និងការទទួលខុសត្រូវខ្ពស់បំផុត ។

Scanned with CamScanner

ថ្ងៃសុក្រ ១០រោច ខែភទ្របទ ឆ្នាំឆ្លូវ ព.ស ២៥៦៥
ធ្វើនៅកណ្ដាល ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១
**ហត្ថលេខា និងត្រានាយកក្រុមហ៊ុន**

NEW ERA (CAMBODIA) CASEMERE TEXTILE CO.,LTD.
KINGDOM OF CAMBODIA

**ស្នាមមេដៃ ប្រតិភូបុគ្គលិក និងប្រធានក្រុមគ្រប់ផ្នែក**

ជុំ ពុទ្ធី    គប ម៉ាឡៃ    ណាក់ សុភ័ក្រ    គប ប៊ុននី    ហេង ធូ    កាន លាងហួយ

សេន សុទ្ធារី    ចៃ សុខគាង    ពេជ្រ សាវ៉េត    ប៉ូ ចាន់ណា    ណាក់សុភ័ក្រ

សាន វិនដា    សូ សារិទ្ធ    គង់សុផល    ខេន កំសត់    លន់ ដាវី    ថា ខ្លឹម

ថៃ ច្រួច    ឯម ស៊ីវន    លិន ចាន់នី    ផន គីមហេង    សុន ស្រីម៉ុម    វ៉ាន ប្រុស

Scanned with CamScanner